# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ៊ា
# ច្បាប់អំពីការសម្លុតធ្វើបាប

*តើការសម្លុតធ្វើបាបជាអ្វី?*

ការសម្លុតធ្វើបាបមានបី (៣) យ៉ាង ដូចតទៅ៖

១. ជាអាកប្បកិរិយាដែលបង្កហេតុអាក្រក់ ឬធ្វើទុក្ខទោស**ដោយចេតនា។**

២. ជាអំពើដែលធ្វើ**ម្តងហើយម្តងទៀត**ក្នុងរយៈពេលយូរ។

៣. ជាអំពើដែលកើតមានឡើងចំពោះមិត្តភាពផ្ទាល់ខ្លួន ដោយសារគ្មានភាពស្មើគ្នា (ដូចជា មនុស្សម្នាក់ ធំជាង ខ្លាំងជាង រហ័សរហួនជាង ឬមានឥទ្ធិពលជាងក្នុងការធ្វើទំនាក់ទំនងក្នុងសង្គម)។

ការសម្លុតធ្វើបាបគឺជា **អំពើធ្វើដោយចំពោះ ឬដោយប្រយោល** អាចមានរួមទាំង តែគ្មានកំណត់ ចំពោះ៖

- **ការធ្វើបាបលើរាងកាយ៖** វាយតប់ ទាត់ធាក់ រុញច្រាន ឬប្រើឲ្យអ្នកណាម្នាក់ ដើម្បីធ្វើឲ្យអ្នកដទៃមានការឈឺចាប់
  **ការប្រើពាក្យសំដី៖** ពាក្យប្រកាន់ពូជសាសន៍ ប្រើឈ្មោះបង្អាប់ និយាយបង្អាប់ និយាយឡកឡឺយ ប្រើពាក្យឬលូកលាន់ផ្លូវភេទ និយាយដើមគេ បង្កើតឲ្យមានពាក្យចចាមអារ៉ាម ឬ
- **ការមិនបញ្ចេញពាក្យសំដី៖** គម្រាមកំហែង កាយវិការអាសអាភាស ធ្វើឲ្យគេឯកោ មិនឲ្យចូលរួមសកម្មភាព តាមរំខាន ការសម្លុតធ្វើបាបតាមគ្រឿងអេឡិចត្រូនិច្ច (ដែលកើតឡើងតាមការប្រើគ្រឿងអេឡិចត្រូនិច្ច ឬ គ្រឿងសម្រាប់ទាក់ទងគ្នា ដូចជា អ៊ីមែល សរសេរឆ្លើយឆ្លងគ្នាភ្លាមៗ សរសេរឆ្លើយឆ្លងគ្នាតាមទូរស័ព្ទដៃ សរសេររឿងខ្លីៗក្នុងកុំព្យូទ័រ ចែកគ្នាមើលរូបថតនិងវីឌីអូ ទាក់ទងគ្នាតាមកុំព្យូទ័រ សរសេរពាក្យអាក្រក់ស្តាប់ក្នុងកុំព្យូទ័រ វ៉ិបសៃ ។ល។)។

*<u>ក្រសួងអប់រំហាមឃាត់ការសម្លុតធ្វើបាបគ្រប់យ៉ាង ដែលប្រព្រឹត្តដោយសិស្សានុសិស្សរបស់ក្រសួង</u>*

*តើអ្នកគួរធ្វើដូចម្តេច បើខ្លួនអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ ត្រូវគេសម្លុតធ្វើបាប?*

**រាយការណ៍ពីឧបត្តិហេតុនៃការសម្លុតធ្វើបាប៖**

សិស្ស ឬ មាតាបិតា/អាណាព្យាបាល របស់សិស្សដែលត្រូវគេសម្លុតធ្វើបាប ឬសាក្សីនៃការសម្លុតធ្វើបាប គួររាយការណ៍ឧបត្តិហេតុនេះ ទៅនាយកសាលា ឬអ្នកតំណាង ឬ សមាជិកដទៃទៀតនៃបុគ្គលិកសាលា រួមទាំង គ្រូបង្រៀន អ្នកផ្តល់ឱវាទ គ្រូកីឡា និងបុគ្គលិករដ្ឋបាល។ បុគ្គលិកណាដែលទទួលសេចក្តីរាយការណ៍នេះ នឹងជម្រាបទៅនាយកសាលា ឬអ្នកតំណាងរបស់គាត់ ជាបន្ទាន់។ ប្រសិនបើការសម្លុតធ្វើបាបនេះនៅតែមានជាបន្ត ឬប្រសិនបើសាលាមិនរកវិធីដោះស្រាយទេនោះ សិស្ស ឬ មាតាបិតា/អាណាព្យាបាល គួររាយការណ៍ឧបត្តិហេតុនេះ ទៅបណ្តាញខ្សែទូរស័ព្ទសម្រាប់ការសម្លុតធ្វើបាបរបស់ក្រសួងអប់រំលេខ ២១៥-៤០០-SAFE។

## *តើនឹងមានអ្វីកើតឡើង នៅពេលឧបត្តិហេតុនៃការសម្លុតធ្វើបាប ត្រូវបានគេរាយការណ៍ហើយ?*

គេនឹងធ្វើការស៊ើបអង្កេតឲ្យបានឆាប់រហ័ស ហើយដោយហ្មត់ចត់ នូវគ្រប់សេចក្តីរាយការណ៍ទាំងអស់។ ប្រសិនបើពាក្យចោទប្រកាន់នេះជាការពិត នាយកសាលា ឬអ្នកតំណាងរបស់គាត់ នឹងធ្វើសកម្មភាពដូចតទៅ៖

១. ផ្តល់ដំណឹងទៅសិស្សដែលសម្លុតធ្វើបាបគេ អំពីលទ្ធផលនៃការស៊ើបអង្កេតនេះ

២. ពិនិត្យមើលឡើងវិញអំពីអត្ថន័យនៃការសម្លុតធ្វើបាប និងច្បាប់របស់ក្រសួងអប់រំ អំពីការសម្លុតធ្វើបាប

៣. ដាក់ទណ្ឌកម្មទៅលើអាកប្បកិរិយានេះទៅតាម ចំនួន និងទម្ងន់ នៃបទល្មើស និង

៤. ផ្តល់ដំណឹងទៅមាតាបិតារបស់សិស្សដែលធ្វើបាបគេ អំពីការប្រព្រឹត្តរបស់សិស្សនោះ និងលទ្ធផលនៃអំពើទាំងនោះ។

## *តើមានអ្វីកើតឡើងដល់សិស្សដែលសម្លុតធ្វើបាបគេ?*

### *លទ្ធផលនៃការល្មើសច្បាប់៖*

សិស្សដែលល្មើសនឹងច្បាប់ សម្លុតធ្វើបាបនឹងត្រូវទទួលវិន័យ ដូចតទៅ៖

- **បទល្មើសលើកទីមួយ៖** រក្សាទុកឯកសារពីការដែលបានព្រមាន និងផ្តល់ដំណឹងឲ្យមាតាបិតាបានដឹង
- **បទល្មើសលើកទីពីរ៖** ប្រជុំជាមួយមាតាបិតា បាត់បង់សិទ្ធិនៅក្នុងសាលា មិនឲ្យចូលរួមក្នុងសកម្មភាពដែលរៀបចំឡើងដោយសាលា ឃាត់ទុក និង/ឬ ទទួលការផ្តល់ឱវាទនៅក្នុងសាលា។
- **បទល្មើសលើកទីបី៖** មិនឲ្យមករៀនមួយរយៈ ឬប្តូរទៅ ថ្នាក់រៀន សាលារៀន ឬរថយន្តដឹកសិស្ស ផ្សេងទៀត។

ប្រសិនបើបទល្មើសលើកទីមួយជាបទល្មើសដែលធ្ងន់ធ្ងរ គេប្រហែលជាដាក់វិន័យដល់សិស្សនោះជាបន្ទាន់ ដោយយោងតាម ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។ ហើយអាចបណ្តាលឲ្យមានការបញ្ឈប់មិនឲ្យមករៀនអស់រយៈពេលយូរ (៥-១០ថ្ងៃ) បញ្ជូនទៅកម្មវិធីអប់រំតាមវិធីផ្សេងទៀត ឬបណ្តេញចេញ។

***ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទាក់ទងមក ការិយាល័យផ្នែក វិន័យ សវនាការ និងការបណ្តេញសិស្សចេញ (Office of Student Discipline, Hearings and Expulsions) លេខ (២១៥) ៤០០-៤២៣០***